# **វិទ្យាល័យ** Franklin Learning Center

-A Pennsylvania Blue Ribbon School of Excellence-
616 N. 15th Street
Philadelphia, PA 19130

***Mrs. Joyce A. Hoog, នាយិកាសាលា*** ***២១៥-៤០០-៧៤៧០, ២១៥-៤០០-៧៤៧១ (ទូរសារ)***

***Mrs. Nicole Lee, នាយិការង***

ខែមករា ឆ្នាំ២០១៧

ជូនចំពោះ មាតាបិតា/អាណាព្យាបាលៈ

កូនរបស់លោកអ្នកបានចុះឈ្មោះចូលរៀននៅ វិទ្យាស្ថានអប់រំសិស្សទើបមកដល់ថ្មី (NLA) នៅ Franklin Learning Center។ Franklin Learning Center គឺជាវិទ្យាល័យទទួលសិស្សដែលមានលក្ខណៈសម្បត្តិពិសេស មានន័យថាសិស្សត្រូវដាក់ពាក្យសុំចូលរៀន ហើយសាលាត្រូវទទួលឲ្យចូលរៀន។ សាលាបានទទួលកូនរបស់លោកអ្នកឲ្យចូលរៀននៅ Franklin Learning Center ដោយសារកូនរបស់លោកអ្នកមានសិទ្ធិចូលរួមក្នុងកម្មវិធី NLA។

NLA គឺជាកម្មវិធីពិសេសសម្រាប់សិស្សវិទ្យាល័យដែលទើបមកដល់ប្រទេសនេះក្នុងពេលថ្មីៗ ហើយទើបតែចាប់ផ្តើមរៀនភាសាអង់គ្លេស។ កម្មវិធី NLA ផ្តោតទៅលើការអភិវឌ្ឍន៍ផ្នែកសង្គម និងការសិក្សាភាសាអង់គ្លេស ក្នុងពេលដែលសិស្សសិក្សាមុខវិជ្ជាសំខាន់ៗ (គណិតវិទ្យា វិទ្យាសាស្ត្រ ។ល។) ដូចបានរៀបរាប់នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាសំខាន់ៗនៅវិទ្យាល័យរបស់ក្រសួងអប់រំ។ គ្រូដែលបង្រៀននៅក្នុងកម្មវិធីនេះបានទទួលការហ្វឹកហ្វឺនពីវិធីសាស្ត្រនៃការបង្រៀនមុខវិជ្ជាដល់សិស្សដែលត្រូវការរៀនភាសាអង់គ្លេស (ELLs) គ្រប់កម្រិតនៃចំណេះដឹងផ្នែកភាសាអង់គ្លេស។

ចាប់ផ្តើមនៅឆ្នាំសិក្សាក្រោយ (២០១៧-១៨) កម្មវិធី NLA នឹងពង្រីកឲ្យទៅជាកម្មវិធីបួនឆ្នាំ នៅសាលា Franklin Learning Center។ នេះមានន័យថា កូនរបស់លោកអ្នកអាចបន្តរៀននៅសាលា Franklin Learning Center រហូតដល់ពួកគេបញ្ចប់ការសិក្សាពីវិទ្យាល័យ។

សូមពិនិត្យមើលការជ្រើសរើសដូចតទៅនេះសម្រាប់កូនរបស់លោកអ្នកៈ

- បើសិនជាកូនរបស់លោកអ្នកចង់បន្តរៀននៅសាលា Franklin Learning Center នៅឆ្នាំសិក្សាក្រោយ (២០១៧-១៨) លោកអ្នកមិនបាច់ធ្វើអ្វីទាំងអស់។
- បើសិនជាកូនរបស់លោកអ្នកបានដាក់ពាក្យសុំទៅរៀននៅវិទ្យាល័យផ្សេងទៀត ហើយសាលានោះព្រមទទួល កូនរបស់លោកអ្នកមានជម្រើសអាចទៅរៀននៅសាលាថ្មី ឬបន្តរៀននៅសាលា Franklin Learning Center ។[១]
- សិស្សានុសិស្សទាំងអស់មានសិទ្ធិជ្រើសរើសទៅរៀននៅវិទ្យាល័យក្នុងតំបន់របស់ខ្លួន។

យើងខ្ញុំសង្ឃឹមថាកូនរបស់លោកអ្នកនឹងបន្តសិក្សានៅសាលា Franklin Learning Center ហើយយើងខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំងចំពោះការពង្រីកកម្មវិធី NLA។ ដើម្បីពន្យល់ពីកម្មវិធី និងការជ្រើសរើសរបស់កូនលោកអ្នក ឲ្យបានកាន់តែច្បាស់លាស់ យើងខ្ញុំនឹងមានអង្គប្រជុំនៅថ្ងៃព្រហស្បតិ៍ ទី២ ខែកុម្ភៈ ឆ្នាំ២០១៧។ សូមអានលិខិតផ្សព្វផ្សាយព័ត៌មានដែលភ្ជាប់មកជាមួយនេះ ដើម្បីជ្រាបពីព័ត៌មានលម្អិត។ នឹងមានផ្តល់ជូនការបកប្រែភាសា។

ដោយសេចក្តីស្មោះស្ម័គ្រ

Joyce Hoog
នាយិកាសាលា
Franklin Learning Center

---

[១] ចាប់ផ្តើមនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ សិស្សានុសិស្ស និងមាតាបិតា អាចប្រើកុំព្យូទ័រដើម្បីចូលមើល ទំព័រវិបសែសម្រាប់សិស្ស ឬមាតាបិតា (Student or Parent Portal) ដើម្បីស្វែងយល់ឲ្យដឹងថាតើពួកគេត្រូវបានគេទទួលឲ្យចូលរៀននៅសាលាផ្សេងទៀតឬអត់។ សិស្សដែលគេទទួលឲ្យចូលរៀននៅវិទ្យាល័យលើសពីមួយ មានពេលប្រាំមួយថ្ងៃដើម្បីជ្រើសរើសសាលាដែលពួកគេចង់ទៅរៀននៅឆ្នាំសិក្សាក្រោយ។ **វិធីនេះ<u>មិន</u>ពាក់ព័ន្ធនឹងសិស្សដែលជ្រើសរើសទៅរៀននៅ Franklin Learning Center ទេ។** សូមនិយាយជាមួយអ្នកផ្តល់ឱវាទនៅ Franklin Learning Center បើសិនជាលោកអ្នកមានសំណួរអ្វី។